**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ :..០១៦ គយ..សជណ/១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដេញថ្លៃការផ្គត់ផ្គង់សម្ភារៈបរិក្ខារប្រើប្រាស់ក្នុងក្រសួងយុត្តិធម៌ ឆ្នាំ ២០១៨

ក្រសួងយុត្តិធម៌ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនសហគ្រាស/( គិតទាំងសហគ្រាសឯកត្តបុគ្គល ) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ ក្រសួងយុត្តិធម៌នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីធ្វើការផ្គត់ផ្គង់សម្ភារៈបរិក្ខារប្រើប្រាស់ក្នុងក្រសួងយុត្តិធម៌ ឆ្នាំ ២០១៨ ។

ក្រសួងយុត្តិធម៌ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មក្រសួងយុត្តិធម៌ ដែលមានអាសយដ្ឋាន ផ្លូវសម្តេចព្រះសុធារស សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ថ្ងៃទី ..២១...... ខែ មិថុនា.. ឆ្នាំ ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅម៉ោង ៣.ម៉.០០..... ថ្ងៃទី ២០..... ខែ ..កក្កដា...... ឆ្នាំ ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ..៣.ម៉.០០........ ថ្ងៃទី ២០...... ខែ កក្កដា.. ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។៚

ថ្ងៃ សុក្រ ១១ កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨
**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានប្រចាំការ**

**កើត សេរាណា**

ចម្លងជូន ៖
- -អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- -ឯកសារ-កាលប្បវត្តិ